## *ក្រឹត្យជនជាតិអាមេរិកាំងដែលពិការ (ADA)*

បើអ្នកគិតថាអ្នកមានភាពពិការ ដែលរាំងរាអ្នកមិនឲ្យស្របតាមសេចក្តីជំរូវរបស់ក្រសួង ឬមានលទ្ធភាពទទួលកម្មវិធីរបស់ក្រសួងបានទេ អ្នកអាចនឹងមានសិទ្ធិទទួលជំនួយ នៅក្រោមក្រឹត្យជនជាតិអាមេរិកាំងដែលពិការ (Americans with Disabilities Act - ADA) ។ នៅក្រោមក្រឹត្យ ADA អ្នកអាចទទួល "ការសំរបសំរួលដោយសមហេតុផល" ឬជំនួយពិសេសពីក្រសួង ។ សូមសួរអ្នកកាន់សំណុំរឿងរបស់អ្នក សំរាប់ព័ត៌មានបន្ថែម ។ អ្នកក៏អាចទាក់ទង នាយកការិយាល័យនៃភាពទីទៃពីគ្នា, ឱកាសស្មើភាពគ្នា និងសិទ្ធិស៊ីវិល (Director of the Office of Diversity, Equal Opportunity and Civil Rights) សំរាប់ជំនួយ ។

## *សេចក្តីថ្លែង ពីការមិនរើសអើង*

ដោយស្របទៅតាមច្បាប់រដ្ឋបាលសហព័ន្ធ ក្រសួងត្រូវបានហាមឃាត់ មិនឲ្យមានការរើសអើង ដោយយោងទៅលើជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ភេទ អាយុ ភាពពិការ សាសនា ឬជំនឿនយោបាយឡើយ ។

**ដើម្បីប្តឹងបណ្តឹងពីការរើសអើង អ្នកអាចទាក់ទងក្រសួងនៅខាងក្រោម :**

***សំរាប់បណ្តឹងជាប់ទាក់ទង- SNAP:***

U.S. Department of Agriculture (USDA)
Director, Office of Adjudication
1400 Independence Avenue, S.W.
Washington, D.C. 20250-9410
1-866-632-9992 (សំឡេង លេខឥតចេញថ្លៃ)
202-401-0216 (TDD)

***សំរាប់បណ្តឹងជាប់ទាក់ទង-TAFDC:***

U.S. Department of Health and Human Services
Office of Civil Rights
JFK Federal Building – Room 1875
Boston, MA 02203
617-565-1340
617-565-1343 (TDD)
617-565-3809 (ទូរសារ)

**អ្នកក៏អាចផ្ញើបណ្តឹងរបស់អ្នក តាមអ៊ី-មេល្យទៅ :**
OCRcomplaint@hhs.gov.

**លើសពីនេះទៅទៀត ក្រសួងក៏ត្រូវបានហាមឃាត់ មិនឲ្យមានការរើសអើង ដោយយោងទៅលើលក្ខណៈការរួមភេទឡើយ ។**

***សំរាប់បណ្តឹងអ្វីមួយជាប់ទាក់ទង-DTA:***

Massachusetts Commission Against Discrimination (MCAD)
One Ashburton Place
Sixth Floor, Room 601
Boston, MA 02108
ទូរស័ព្ទ: (617) 994-6000
TTY: (617) 994-6196

Department of Transitional Assistance
Office of Diversity, Equal Opportunity and Civil Rights
600 Washington Street
Boston, MA 02111
617-348-8490 (សំឡេង)
617-348-5532 (TTY)

YRTK-Khmer (Rev. 6/2010)
18-134-0610-05

Commonwealth of Massachusetts
ក្រសួងជំនួយនៃការផ្លាស់ប្តូរ

# *ត្រូវដឹងសិទ្ធិរបស់អ្នក*

ឃោសនាប័ណ្ណនេះ ពន្យល់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក បើអ្នកទទួលអត្ថប្រយោជន៍(ជំនួយ)ពីក្រសួង រួមទាំងជំនួយការផ្លាស់ប្តូរសំរាប់គ្រួសារដែលមានកូនក្នុងបន្ទុក (Transitional Aid to Families with Dependent Children - TAFDC), ជំនួយជាអាសន្នសំរាប់ចាស់ទុំ, ជន់ពិការ និងក្មេងៗ (Emergency Aid to the Elderly, Disabled and Children - EAEDC), និង/ឬ អត្ថប្រយោជន៍កម្មវិធីជំនួយអាហារមានជីវជាតិបន្ថែម (Supplemental Nutrition Assistance Program - SNAP) ដែលពីមុនហៅថា កម្មវិធីហ្វូតស្តែម (Food Stamp Program) ។ សូមអានវាដោយយ៉ាងប្រិតប្រៀង ។ អ្នកក៏នឹងត្រូវអានឃោសនាប័ណ្ណរបស់កម្មវិធី សំរាប់កម្មវិធីជាក់លាក់និមួយៗ ដើម្បីទទួលព័ត៌មានសំខាន់ៗផងដែរ ។ អ្នកគឺទទួលខុសត្រូវ ដើម្បីប្រាប់សមាជិកក្នុងក្រុមគ្រួសាររបស់អ្នក អំពីច្បាប់របស់កម្មវិធី ព្រមទាំងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់គេ ។ បើអ្នកមិនយល់អ្វីមួយ ត្រូវកុំខានស្នើអ្នកកាន់សំណុំរឿងរបស់អ្នកឲ្យពន្យល់អ្នក ។ បើសិនអ្នកជាអ្នកគ្មានសញ្ជាតិ ត្រូវធ្វើឲ្យប្រាកដថាអ្នកកាន់សំណុំរឿងរបស់អ្នក ផ្តល់ឲ្យអ្នកនូវឃោសនាប័ណ្ណមានចំណងជើងថា "អ្វីៗដែលអ្នកគ្មានសញ្ជាតិត្រូវដឹង" (What Noncitizens Need to Know) និង "ធនធានសំរាប់អ្នកគ្មានសញ្ជាតិ" (Noncitizen Resources) ។

## *ការទទួលខុសត្រូវរបស់អ្នក*

អាស្រ័យទៅលើច្បាប់របស់កម្មវិធី ដែលអ្នកចូលរួម អ្នកត្រូវតែ :

- ផ្តល់ព័ត៌មានសព្វគ្រប់ និងត្រឹមត្រូវ ទៅឲ្យក្រសួង ។
- រក្សាការណាត់ពេលជួបរបស់អ្នក ។ បើអ្នកត្រូវការគ្រោងពេលវេលាជាសាថ្មី ត្រូវទាក់ទងអ្នកកាន់សំណុំរឿងរបស់អ្នក យ៉ាងឆាប់រហ័សបំផុត ។
- បញ្ចប់ការពិនិត្យពិច័យសិទ្ធិទទួលដែលបានគ្រោងពេល (អ្នកអាចនឹងបានទាក់ទងនៅពេលផ្សេងទៀត សំរាប់មូលហេតុផ្សេងទៀត) ។
- សហការជាមួយនឹងបុគ្គលិករដ្ឋាភិបាល ដែលជាអ្នកត្រូវពិនិត្យពិច័យសំណុំរឿងរបស់អ្នក ។
- ប្រាប់ក្រសួង អំពីការផ្លាស់ប្តូរអ្វីមួយដែលអាចនឹងប៉ះពាល់ដល់អត្ថប្រយោជន៍របស់អ្នក ដោយមានរួមទាំង ប៉ុន្តែមិនកំរិតទៅលើ :
  ⇒ចំនួនមនុស្សដែលរស់នៅជាមួយអ្នក;
  ⇒ទីកន្លែងដែលអ្នករស់នៅ (អាសយដ្ឋានរបស់អ្នក) និងដំឡៃទឹកភ្លើង ឬទីជំរក (រួមទាំង ផ្នែកទី 8 ឬកម្មវិធីប្រាក់ឧបត្ថម្ភផ្សេងទៀត);
  ⇒ការធានារ៉ាប់រងសុខភាពរបស់អ្នក (ឧទាហរណ៍ បើអ្នកទទួលការធានារ៉ាប់រងសុខភាពថ្មី តាមរយៈការងារ ឬពីមាតាបិតាដែលអវត្តមាន, ឬបើអ្នកបាត់បង់ការធានារ៉ាប់រងសុខភាពរបស់អ្នក);
  ⇒ចំនួនប្រាក់ដែលរកបាន, ប្រាក់សូស្យាល់សឺគួរិទី, ប្រាក់សុទ្ធ ឬប្រាក់ឧបត្ថម្ភកូនដែលអ្នកទទួល; ឬ
  ⇒ប្រាក់អ្វីមួយដែលអ្នកទទួល ដូចជាប្រាក់ទូទាត់គ្នា, ប្រាក់សូស្យាល់សឺគួរិទីបកក្រោយ, ឬការឈ្នះឆ្នោត ។

អ្នកត្រូវតែរាយការណ៍ពីការផ្លាស់ប្តូរទៅក្រសួង តាមរយៈការសរសេរសំបុត្រ ទូរស័ព្ទ ឬដោយផ្ទាល់មុខ ក្នុងពេល 10 ថ្ងៃនៃការផ្លាស់ប្តូរ ។ បើអ្នកមិនរាយការណ៍ពីការផ្លាស់ប្តូរទាំងនេះទេ អ្នកអាចនឹងបាត់បង់អត្ថប្រយោជន៍របស់អ្នក ។ បើអ្នកមិនប្រាកដ ថាអ្នកត្រូវតែរាយការណ៍ព័ត៌មានឬជាយ៉ាងណា ត្រូវសួរអ្នកកាន់សំណុំរឿងរបស់អ្នក ឬទូរស័ព្ទទៅលេខ 1-800-445-6604 ។

អាស្រ័យទៅលើច្បាប់របស់កម្មវិធី អ្នកក៏អាចនឹងបានជំរូវឲ្យ :

- ចូលរួមក្នុងកម្មវិធីសេវាការងាររបស់ក្រសួង (Department's Employment Services Program) ឬស្វែងរកការងារ; និង
- ចុះហត្ថលេខាឲ្យបញ្ចេញឯកសារពេទ្យ ។

បើអ្នកកំពុងតែស្វែងរកអត្ថប្រយោជន៍ទីលំនៅ ឬទីជំរក សូមទាក់ទងក្រសួងវឌ្ឍនកម្មទីលំនៅ និងសហគមន៍ ផ្នែកខាងស្ថិរភាពទីលំនៅ (Department of Housing and Community Development's Division of Housing Stabilization) តាមលេខ 1-877-418-3308 (សំឡេង) ឬ 617-573-1140 (TTY) ។

## *សិទ្ធិរបស់អ្នក*

អ្នកមានសិទ្ធិដើម្បី :

- ត្រូវបានគេប្រព្រឹត្តមកលើដោយគួរសម និងគោរព;
- បំពេញក្រដាសដាក់ពាក្យសុំ;
- ឲ្យបានសំរេចអំពីសិទ្ធិទទួលអត្ថប្រយោជន៍របស់អ្នក យ៉ាងឆាប់រហ័ស (តាមធម្មតាក្នុងពេល 30 ថ្ងៃ);
- ទទួលសេចក្តីជូនដំណឹងពីក្រសួង អំពីការសំរេចទៅលើការដាក់ពាក្យសុំរបស់អ្នក និងរាល់វេលាមានការផ្លាស់ប្តូរចំពោះសំណុំរឿងរបស់អ្នក;
- ទទួលអត្ថប្រយោជន៍ ចាប់តាំងពីថ្ងៃអ្នកបានដាក់ពាក្យសុំ បើសិនជាក្រុមគ្រួសាររបស់អ្នកមានសិទ្ធិទទួល;
- ទទួលអ្នកបកប្រែ ដែលបានផ្តល់ដោយក្រសួង បើសិនជាត្រូវការ;
- ទទួលជំនួយម្ហូបអាហារ និងការថែទាំសុខភាពភ្លាមៗ បើសិនជាអ្នកមានសិទ្ធិទទួល;
- ទទួលជំនួយបញ្ហាអំពើហិង្សាក្នុងគ្រួសារ;
- ប្តឹងតវ៉ា បើសិនជាអ្នកមិនយល់ស្របជាមួយនឹងការសំរេចអ្វីមួយទៅលើសំណុំរឿងរបស់អ្នក (ដើម្បីតវ៉ា ត្រូវបំពេញក្រដាសបំពេញ នៅខាងខ្នងនៃសេចក្តីជូនដំណឹងដែលអ្នកទទួលពីក្រសួង; បើសិនអ្នកបាត់សេចក្តីជូនដំណឹង ត្រូវទាក់ទងអ្នកកាន់សំណុំរឿងរបស់អ្នក ដើម្បីយកក្រដាសបំពេញតវ៉ាមួយទៀត);
- ពិនិត្យមើលសំណុំរឿងរបស់អ្នកឡើងវិញ;
- មានអ្នកតំណាងបានអនុញ្ញាត ដើម្បីជួយអ្នក; និង
- ទទួលការសំរបសំរួលដោយសមហេតុផល (ជំនួយពិសេស) បើសិនអ្នកជាជនពិការ ។

## *អំពីរបៀបទទួលអត្ថប្រយោជន៍របស់អ្នក*

អ្នកនឹងទទួលអត្ថប្រយោជន៍របស់អ្នក តាមរយៈបញ្ចូលផ្ទាល់ទៅកុងធនាគាររបស់អ្នក ឬតាមរយៈការផ្ទេរអត្ថប្រយោជន៍ជាអេឡិកត្រូនិក (Electronic Benefit Transfer - EBT) ។ ជាមួយនឹង EBT អ្នកដកយកអត្ថប្រយោជន៍ប្រាក់របស់អ្នកពី ATM (ម៉ាស៊ីនធនាគារ) ។ អ្នកអាចប្រើប្រាក់ និង/ឬ អត្ថប្រយោជន៍ SNAP របស់អ្នក នៅតាមចំណុចលក់ដូរ (POS) (កន្លែងគិតលុយ) ក្នុងហាងទំនិញធំៗ និងតាមហាងផ្សេងៗទៀត ។ អ្នកអាចមានអ្នកណាម្នាក់ ដើម្បីទទួលអត្ថប្រយោជន៍ជំនួសអ្នកបាន ។ មនុស្សនេះនឹងហៅថា អ្នកទទួលប្រាក់ ឬអ្នកតំណាងបានអនុញ្ញាត ។ ត្រូវពិគ្រោះជាមួយនឹងអ្នកកាន់សំណុំរឿងរបស់អ្នក អំពីការជ្រើសរើសនេះ ។ បើសិនជាអ្នកមានកុងធនាគារ អ្នកត្រូវតែទទួលអត្ថប្រយោជន៍ប្រាក់របស់អ្នក តាមរយៈការបញ្ចូលផ្ទាល់ ។

## *ការប្រើប្រាស់ព័ត៌មានរបស់អ្នក*

ក្រសួងអាចនឹងទាក់ទងទៅមនុស្ស ឬភ្នាក់ងារផ្សេងៗទៀត ដើម្បីពិនិត្យមើលព័ត៌មានដែលអ្នកផ្តល់ឲ្យ ។ ព័ត៌មានដែលអ្នកផ្តល់ឲ្យ នឹងត្រូវទទួលការបញ្ជាក់ដោយរដ្ឋបាលសហព័ន្ធ រដ្ឋ និងអ្នកមុខអ្នកការក្នុងតំបន់ និងតាមរយៈប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យរដ្ឋាភិបាល ។





## *លេខសូស្យាល់សឺគួរទី និងសិទ្ធិ របស់អ្នក ចំពោះភាពឯកជន*

សមាជិកក្រុមគ្រួសារដែលដាក់ពាក្យសុំ ដើម្បីទទួលជំនួយ បានដំរូវឲ្យផ្តល់លេខសូស្យាល់សឺគួរិទីរបស់គេទៅឲ្យក្រសួង ។ លេខទាំងនេះនឹងបានបញ្ជាក់ ។ សមាជិកក្រុមគ្រួសារដែលគ្មានលេខសូស្យាល់សឺគួរិទី នឹងបានបញ្ជូនទៅការិយាល័យ នាយកដ្ឋានសូស្យាល់សឺគួរិទី (Social Security Administration) ក្នុងតំបន់ ដើម្បីដាក់ពាក្យសុំ ។ អ្នកកាន់សំណុំរឿងរបស់អ្នក នឹងជួយអ្នកក្នុងបញ្ហានេះ ។

នៅពេលអ្នកចុះហត្ថលេខាលើក្រដាសដាក់ពាក្យសុំរបស់អ្នក គឺអ្នកកំពុងតែផ្តល់ការអនុញ្ញាតឲ្យក្រសួង ដើម្បីប្រើលេខសូស្យាល់សឺគួរិទីនៃក្រុមគ្រួសាររបស់អ្នក ដើម្បីតាមដានសំណុំរឿងរបស់អ្នក និងការពារនូវការទទួលអត្ថប្រយោជន៍ជាពីរដង ។

ដើម្បីបញ្ជាក់ព័ត៌មានដែលអ្នកផ្តល់ឲ្យ ក្រសួងអាចនឹងផ្ទៀងផ្ទាត់លេខសូស្យាល់សឺគួរិទី របស់សមាជិកក្រុមគ្រួសារ ជាមួយនឹងឯកសាររបស់ :

- រដ្ឋបាលសហព័ន្ធ រដ្ឋ ស្រុក ឬភ្នាក់ងារណាមួយក្នុងតំបន់;
- ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត;
- ក្រសួងអ្នកផ្តល់សេវា; និង
- ភ្នាក់ងារ ឬស្ថាប័នផ្សេងទៀត តាមច្បាប់បានអនុញ្ញាត ។

## *អ្នកគ្មានសញ្ជាតិ*

ដើម្បីឲ្យមានសិទ្ធិទទួលអត្ថប្រយោជន៍ TAFDC, EAEDC ឬ SNAP បាន អ្នកគ្មានសញ្ជាតិត្រូវតែបញ្ជាក់ថាគេរស់នៅក្នុងសហរដ្ឋដោយស្របច្បាប់ ។ បើសិនជាអ្នកមានសំណួរអ្វី អំពីស្ថានភាពអ្នកគ្មានសញ្ជាតិ សូមសួរអ្នកកាន់សំណុំរឿងរបស់អ្នក ។

នៅក្រោមច្បាប់ TAFDC និង SNAP អ្នកគ្មានសញ្ជាតិ ដែលពុំអាច ឬមិនចង់ផ្តល់ព័ត៌មានស្ថានភាពអន្តោប្រវេសន៍ ឬលេខសូស្យាល់សឺគួរិទីបាន ដោយព្រោះស្ថានភាពអន្តោប្រវេសន៍ មិនបាច់ធ្វើដូច្នេះទេ ។ តែជាយ៉ាងណាមិញ អ្នកគ្មានសញ្ជាតិនេះ នឹង**មិន**មានសិទ្ធិទទួលអត្ថប្រយោជន៍ឡើយ ។ សមាជិកក្រុមគ្រួសារដទៃទៀតនៅអាចទទួលអត្ថប្រយោជន៍បាន ។

បើអ្នកក្លាយជាសញ្ជាតិអាមេរិក អ្នកអាចនឹងមានសិទ្ធិទទួលអត្ថប្រយោជន៍ពីរដ្ឋបាលសហព័ន្ធ ដូចជាប្រាក់ចំណូលសឺគួ-រិទីបន្ថែម (Supplemental Security Income - SSI) ។ ជាទូទៅ អ្នកត្រូវតែជាអ្នកមូលដ្ឋានអចិន្ត្រៃយ៍ចំនួនប្រាំឆ្នាំ (បីឆ្នាំបើរៀបការជាមួយនឹងអ្នកមានសញ្ជាតិអាមេរិក) មុនពេលអ្នកមានសិទ្ធិចូលសញ្ជាតិបាន ។ អ្នកអាចដាក់ពាក្យសុំ 90 ថ្ងៃមុនដល់ពេលអ្នកបានស្របតាមសេចក្តីដំរូវប្រាំឆ្នាំ ។ អ្នកនឹងត្រូវបង្ហាញនូវចំណេះដឹងភាសាអង់គ្លេស និងប្រវត្តិសាស្ត្រខ្លះនៃសហរដ្ឋអាមេរិក លុះត្រាតែអ្នកមានមានសិទ្ធិទទួលការវៀរបង់ ពីព្រោះអ្នកមានភាពពិការផ្លូវចិត្ត ឬរូបកាយ ដែលរាំងរាអ្នកមិនឲ្យអាចសិក្សាបាន ។ ជាទូទៅ វានឹងប្រើពេលប្រហែលមួយឆ្នាំ ទើបអ្នកអាចដាក់ពាក្យសុំ និងធ្វើសំភាសន៍ចូលសញ្ជាតិរបស់អ្នក ។ ការពិនិត្យប្រវត្តិរូបបន្ថែម ដោយព្រោះបញ្ហាសន្តិសុខបានកើនឡើង អាចនឹងមានន័យថាវាអាចប្រើពេលយូរជាង ។

វាគឺជាសារៈសំខាន់ ដើម្បីទទួលជំនួយ<u>មុនពេល</u>អ្នកដាក់ពាក្យសុំចូលសញ្ជាតិ ។ ការិយាល័យសំរាប់ជនភៀសខ្លួន និងជនអន្តោប្រវេសន៍ (Office for Refugees and Immigrants - ORI) ធ្វើការជាមួយនឹងបណ្តាញនៃអង្គការនានាក្នុងសហគមន៍ ដែលចូលរួមក្នុង ផែនការផ្សព្វផ្សាយសញ្ជាតិភាព (Citizenship Outreach Project) ។ អង្គការទាំងនេះនឹងត្រួតពិនិត្យមើលសិទ្ធិចូលសញ្ជាតិ ផ្តល់ជំនួយចំពោះវិធីសញ្ជាតូបនីយកម្ម និង/ឬ ធ្វើការបញ្ជូនដោយសមរម្យ ។ អ្នកកាន់សំណុំរឿងនៅក្រសួងជំនួយនៃការផ្លាស់ប្តូររបស់អ្នក អាចផ្តល់ឲ្យអ្នកនូវបញ្ជីឈ្មោះ អង្គការដែលអាចជួយអ្នកក្នុងការដាក់ពាក្យសុំចូលសញ្ជាតិ ។